# អ៊ុនតាក់៖ សង្គ្រាម, មីន, អំពើប្រល័យពូជសាសន៍

# UNTAC: War, Landmine, Genocide




## FULL OF HOPE WITH UNTAC

Youk Chhang, Director of Documentation Center of Cambodia

At the invitation from Professor William Maley, Director, Asia-Pacific College of Diplomacy of Australian Nation University, College of Asia and the Pacific, I went to both Melbourne and Canberra for the UNTAC 20th anniversary of elections in Cambodia, and in preparation for this meeting, I fell upon some old photographs, one of which I include here.

Looking at this photo, you see that I was a brash young Cambodian-American with half-military, half-civilian personalities. Based on my posture and the way I wore my flak vest, you would think that I was cool and comfortable in my surroundings. I even cracked a grin for the camera. But appearances can be deceiving. I was assigned to Phnom Srouch district in Kampong Speu province as UNTAC international staff in support of the election (1992-1993). During the UNTAC election, there were 101 polling stations and my area covered a population of approximately 250,000 voters.

Half of Kampong Speu province was still under the control of the Khmer Rouge at that time, and as a Cambodian with native fluency in Khmer, I was a threat to the Khmer Rouge, who were seeking to block the election. I could communicate to the voters and listen to the Khmer Rouge radio communications on my walkie-talkie. I was comfortable and adept with navigating the local culture, and the ordinary people knew me as one of them. (my code was Echo15 throat fish). But Phnom Srouch district was a tough place in 1993 – the district at that time was totally within Khmer Rouge

territory, and the area was saturated with land mines. It was truly a scary place to be. I had many threats against my life. The Khmer Rouge planted a landmine, just before my arrival, outside the bathroom to the pre-fabricated building that was my work area.

To my sadness, one of my team-mates triggered the mine and lost his leg. My car broke down one day in the jungle and I didn't know how to fix it. In truth, it was my fault. I did not understand I had to change the oil in my vehicle back then. I just drove the car endlessly until one day the engine just blew up. With smoke pouring out of the engine, I radioed the UN for assistance. Assistance came, but not until the next morning.
My car broke down just shortly after a Khmer Rouge patrol had passed. If it had broken down just a bit earlier, I would have been captured and killed. The UN security forces had pity on many of us and I received the flak vest shown in the photo. It was old issue from the Bulgarian Army. It was so hot in those days that I couldn't bear to wear it properly. It's a wonder as to whether it really would have saved me anyway, but it looked cool and so I wore it for the appearance.

In my area, under UN control, the Bulgarian Army provided security while the Australian Army managed the military communication networks (call sign: FCU Kampong Speu, SPOE Emergency).

I look back on how crazy, adventurous and dangerous those days were, and how crucial our efforts were to the future of Cambodia. The Khmer Rouge were real menaces back then. They terrorized the population and murdered people in cold blood. But look at where we are today. Over time, nearly all of them defected and now their leaders are being tried for genocide, crimes against humanity and war crimes by the Extraordinary Chambers in the Courts of Cambodia (ECCC).

It was a long, difficult struggle, and I was young, brash and crazy back then; but sometimes the world needs a little bit of youthful craziness.

This article has been published by the Phnom Penh Post on May 29, 2013

Photo caption: Youk Chhang in Kampong Speu province in 1993. Photo by Brigitte

## អ៊ុនតាក់ពោរពេញទៅដោយក្តីសង្ឃឹម

ដោយ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

តាមរយៈសេចក្តីអញ្ជើញពីសាស្ត្រាចារ្យ វីលៀម ម៉ាលី នាយកមហាវិទ្យាល័យការទូតនៃអាស៊ីប៉ាស៊ីហ្វិករបស់សាកលវិទ្យាល័យជាតិអូស្ត្រាលី ខ្ញុំបានធ្វើដំណើរទៅកាន់ទីក្រុងមែលប៊ើន និងរដ្ឋធានីកង់បេរ៉ា ដើម្បីចូលរួមខួបលើកទី២០នៃការបោះឆ្នោតនៅប្រទេសកម្ពុជា ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា ហៅកាត់ថា អ៊ុនតាក់។ នៅពេលដែលខ្ញុំកំពុងត្រៀមកិច្ចការមួយចំនួនសម្រាប់ ខួបលើកទី២០នេះ ខ្ញុំបានបើកមើលរូបថតចាស់ៗមួយចំនួនពីសម័យអ៊ុនតាក់ រួមទាំងរូបថតមួយសន្លឹកនៅក្នុងអត្ថបទនេះផង។

តាមរយៈរូបថតនេះ អ្នករាល់គ្នាអាចយល់បានថា កាលនោះខ្ញុំជាយុវជនខ្មែរអាមេរិកាំងវ័យក្មេងម្នាក់ក្នុងសម្លៀកបំពាក់ពាក់កណ្តាលយោធា និងពាក់កណ្តាលស៊ីវិល។ តាមរយៈកាយវិការនិងអាវការពារគ្រាប់កាំភ្លើងដែលខ្ញុំពាក់ អ្នករាល់គ្នាអាចគិតថា ខ្ញុំមានសុវត្ថិភាពចំពោះហេតុការណ៍ទាំងឡាយ នៅជុំវិញខ្លួនខ្ញុំ។ ខ្ញុំបានញញឹមតិចៗដាក់ម៉ាស៊ីនថត។ ប៉ុន្តែ អ្វីដែលអ្នករាល់គ្នាមើលឃើញគ្រាន់តែជាការបំភាន់តែប៉ុណ្ណោះ។ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅ ប្រចាំការនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនាមជាបុគ្គលិកអន្តរជាតិរបស់អ៊ុនតាក់ ដើម្បីរៀបចំការបោះឆ្នោតក្នុងអំឡុងពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣។ ក្នុងអំឡុងពេលបោះឆ្នោតដែលបានរៀបចំឡើងដោយអ៊ុនតាក់ មានការិយាល័យបោះឆ្នោតចំនួន១០១កន្លែង ហើយទីតាំងដែលខ្ញុំប្រចាំការមានអ្នក បោះឆ្នោតចំនួន២សែន៥ម៉ឺននាក់។

កាលនោះ ពាក់កណ្តាលនៃផ្ទៃដីខេត្តកំពង់ស្ពឺទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហមនៅឡើយ ហើយក្នុងនាមជាជនជាតិ ខ្មែរម្នាក់ ខ្ញុំគឺជាគោលដៅគំរាមកំហែងរបស់ខ្មែរក្រហមដែលរារាំងមិនឲ្យមានការបោះឆ្នោត។ ដោយមូលហេតុនេះ ខ្ញុំអាចទាក់ទងជាមួយម្ចាស់ឆ្នោត និងស្តាប់វិទ្យុទាក់ទងខ្មែរក្រហមបានតាមរយៈអាយកូមរបស់ខ្ញុំ។ តាមរយៈឧបករណ៍នេះ ខ្ញុំមានអារម្មណ៍ស្រួលចិត្ត និងមានភាពស្ទាត់ជំនាញក្នុងការ បត់បែនតាមបែបផែននិងជីវភាពរស់នៅរបស់អ្នកស្រុក ហើយអ្នកភូមិមូលដ្ឋានរាប់អាន និងចាត់ទុកខ្ញុំជាអ្នកភូមិម្នាក់នៅក្នុងស្រុកភូមិដែរ។ កាលនោះ លេខកូដអាយកូមរបស់ខ្ញុំ គឺ អេកូ១៥ throat fish (បំពង់កត្រី)។ ស្រុកភ្នំស្រួចគឺជាតំបន់ដ៏តានតឹងក្នុងឆ្នាំ១៩៩៣ ដែលកាលនោះតំបន់នោះស្ថិតក្នុង ទឹកដីគ្រប់គ្រងដោយកងទ័ពខ្មែរក្រហម។ តំបន់នោះពោរពេញទៅដោយគ្រាប់មីន និងជាទីតាំងដ៏គ្រោះថ្នាក់។ ខ្ញុំទទួលរងនូវការគំរាមកំហែងជាច្រើនលើក ច្រើនសាពីសំណាក់ខ្មែរក្រហម។ ម្តងនោះ មុននឹងខ្ញុំទៅដល់ការិយាល័យរបស់ខ្ញុំ ខ្មែរក្រហមបានចូលមកបង្កប់គ្រាប់មីនតាមផ្លូវដើរពីបន្ទប់ទឹកទៅបន្ទប់ការិយាល័យរបស់ខ្ញុំ ដែលជាបន្ទប់មានរាងដូចឃ្លាំងទំនិញ។

ជាអកុសល បុគ្គលិករបស់ខ្ញុំម្នាក់បានដើរជាន់មីននោះធ្វើឲ្យគាត់ទទួលរងរបួសធ្ងន់ និងពិការជើង។ គ្រាមួយនោះ រថយន្តរបស់ខ្ញុំបានខូចនៅ ក្នុងព្រៃពេញមួយថ្ងៃ ហើយខ្ញុំមិនចេះជួសជុលរថយន្តទេ។ តាមការពិត នេះជាកំហុសរបស់ខ្ញុំ។ ខ្ញុំមិនដឹងថា ខ្ញុំគួរតែប្តូរប្រេងម៉ាស៊ីនរថយន្ត។ ខ្ញុំចេះតែបើករថយន្តទៅមុខរហូតទាល់តែថ្ងៃមួយរថយន្តនោះផ្ទុះ

ផ្សែងចេញមកក្រៅ ទើបខ្ញុំដឹងថារថយន្តនោះខូច។ ដោយឃើញមានផ្សែងចេញពីម៉ាស៊ីនរថយន្ត ខ្ញុំក៏ប្រើវិទ្យុទាក់ទងទៅប៉ូលីសអង្គការសហប្រជាជាតិដើម្បីសុំជំនួយ។ ទាល់តែមួយថ្ងៃក្រោយមកទើបប៉ូលីសអង្គការសហប្រជាជាតិម្នាក់បានមកដល់។

រថយន្តរបស់ខ្ញុំបានខូចក្រោយពេលដែលកងទ័ពខ្មែរក្រហមដើរល្បាតឆ្លងកាត់តំបន់នោះបានមួយស្របក់។ ប្រសិនបើរថយន្តរបស់ខ្ញុំខូចមុននោះ តែបន្តិច ម្ល៉េះខ្ញុំត្រូវខ្មែរក្រហមចាប់ និងសម្លាប់បាត់ទៅហើយក៏មិនដឹង។ ពេលខ្ញុំប្រាប់ពីដំណឹងនេះ ផ្នែកសន្តិសុខអង្គការសហប្រជាជាតិមានក្តីបារម្ភ ពីសុវត្ថិភាពរបស់ក្រុមយើងជាខ្លាំង ហើយក៏ប្រគល់អាវក្រោះមួយតូចដូចឃើញនៅក្នុងរូបថតនេះ។ អាវក្រោះការពារគ្រាប់កាំភ្លើងនេះគឺជាអាវសេរីចាស់ យកមកពីកងយោធារបស់ប្រទេសប៊ុលហ្គារី។ ពេលនោះ អាកាសធាតុក្តៅណាស់ធ្វើឲ្យខ្ញុំមិនអាចពាក់អាវនោះឲ្យបានជាប់លាប់ទេ។ ខ្ញុំមិនដឹងថាអាវនេះ អាចជួយជីវិតខ្ញុំបានប៉ុណ្ណាទេ តែអាវនោះមានចរិតឡូយ ហើយខ្ញុំពាក់អាវនេះដោយសារតែវាមានរាងសមនឹងខ្ញុំ។

នៅកន្លែងដែលខ្ញុំប្រចាំការកាលពីជំនាន់អ៊ុនតាក់ កងយោធាប៊ុលហ្គារីមាននាទីរក្សាសន្តិសុខ ចំណែកឯកងយោធារបស់អូស្ត្រាលីមាននាទីទំនាក់ ទំនងបណ្តាញយោធា។ សញ្ញាណហៅចូលគឺ FCU កំពង់ស្ពឺ SPOE បន្ទាន់។

នៅពេលសម្លឹងទៅមើលអតីតកាល ខ្ញុំអាចនិយាយបានថា កាលនោះស្ថានភាពមានភាពគ្រោះថ្នាក់និងផ្សងព្រេងជាខ្លាំង តែជាមួយគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងរបស់យើងពិតជាមានសារសំខាន់ណាស់សម្រាប់អនាគតប្រទេសកម្ពុជា។ ពេលនោះ ខ្មែរក្រហមបានធ្វើការគំរាមកំហែងយ៉ាងពិត ប្រាកដ។ ខ្មែរក្រហមបានបំភិតបំភ័យនិងបន្តសម្លាប់ប្រជាជនដោយកំហឹង។ តែបើយើងក្រឡេកមកមើលពេលបច្ចុប្បន្នវិញ ខ្មែរក្រហមស្ទើរតែទាំងអស់ បានផ្តាច់ខ្លួននិងបានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយនៅខណៈនេះមេដឹកនាំខ្មែរក្រហមកំពុងតែទទួលការកាត់ទោសក្រោមបទប្រល័យ ពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

នេះគឺជាការតស៊ូដ៏ស្វិតស្វាញនិងវែងឆ្ងាយមួយ ហើយកាលនោះដែរ ខ្ញុំជាយុវជនវ័យក្មេងក្រអឺតក្រទមនិងលីលាម្នាក់ ប៉ុន្តែពេលខ្លះពិភពលោកចង់បានភាពលីលារបស់យុវជនបែបនេះ៕

អត្ថបទនេះបានបោះពុម្ពផ្សាយជាភាសាអង់គ្លេសដោយកាសែតភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣។
រូបថត: ផាំង យុ នៅខេត្តកំពង់ស្ពឺ ឆ្នាំ១៩៩៣ ថតដោយ Brigitte



រូបពីឆ្វេងទៅស្តាំៈ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៀ បាញ់, តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ យ៉ាសុស៊ី អាកាស៊ី, ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះប្រធានឧត្តមក្រុមប្រឹក្សាជាតិ ចូលរួមពិធីស្វាគមន៍ការវិលត្រឡប់របស់ជនភៀសខ្លួនកម្ពុជានៅទីក្រុងភ្នំពេញ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩២។ រូបថតៈ P Sudhakaran I ប្រភពៈ Benny Widyono

From Left to right: Tear Banh, Deputy Prime Minister and Minister of National Defense, Yasushi Akashi, Special Representative of the Secretary-General for Cambodia, Prince Norodom Sihanouk, President of the Supreme National Council, attending a welcoming ceremony for Cambodian returnees in Phnom Penh on September 28, 1992. Photo: P Sudhakaran I Source: Benny Widyono




បុរសម្នាក់ធ្វើត្រាប់តាមរូបផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដោយបានលើកបង្ហាញបណ្ណចុះឈ្មោះបោះឆ្នោតអ៊ុនតាក់របស់គាត់។ រូបថតនេះថតនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩២។ រូបថត: P Sudhakaran ប្រភព: Benny Widyono

Mimicking the scene in a voter registration billboard, a Cambodian man displays UNTAC his registration card. The photo was taken on September 01, 1992. Photo: P Sudhakaran I Source Benny Widyono



បុរសម្នាក់កំពុងផ្ទៀងស្តាប់ការផ្សាយ
តាមវិទ្យុដែលឧបត្ថម្ភដោយអង្គការ
ក្រៅរដ្ឋាភិបាលមួយរបស់ជប៉ុន
និងចែកចាយដោយការិយាល័យ
ព័ត៌មាន និងអប់រំរបស់អ៊ុនតាក់។
អ៊ុនតាក់បានប្រើប្រាស់វិទ្យុក្នុងការ
ផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត
ដែលនឹងមកដល់នៅខែឧសភា
ឆ្នាំ១៩៩៣។
រូបថត: អង្គការសហប្រជាជាតិ
នៅខេត្តកំពង់ស្ពឺ នៅថ្ងៃទី១ ខែតុលា
ឆ្នាំ១៩៩២។
ប្រភព: Benny Widyono

A Cambodian listening to a radio donated by a Japanese non-governmental organization and distributed byUNTAC's information and education division.  UNTAC was using radio to convey information about the upcoming election, scheduled for May 1993. Photo: UN Photo/P in Kampong Speu Province on October 01, 1992 I Source: Benny Widyono



United Nations Transitional Force in Cambodia, Khamchay Mea, 13/06/1992. Phase Two of the cease-fire in Cambodia became effective today. Under Phase Two, the responsibilities of UNTAC include supervising the cease-fire, cantoning and demobilizing the forces of the four Cambodian factions. UNTAC was established by Security Council resolution 745 ( 1992 ) and became operational 15 March 1992. UNTAC is mandated with guiding Cambodia through its transitional period to free and fair elections in April/May 1993 which will establish a new democratic Government.
Photo: UN Photo/P I Source: Benny Widyono

កងកម្លាំងបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា, ស្រុកកំចាយមារ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩២។ ដំណាក់កាលទីពីរនៃបទឈប់បាញ់នៅកម្ពុជាមានសុពលភាពចាប់ពីថ្ងៃនេះតទៅ។ នៅក្នុងដំណាក់កាលទីពីរនេះ ការទទួលខុសត្រូវរបស់ អ៊ុនតាក់រួមមាន ការត្រួតពិនិត្យបទឈប់បាញ់ ការដាក់ទ័ពបណ្តោះអាសន្ន ការរំសាយទ័ពពីភាគីទាំងបួនរបស់កម្ពុជា។ អ៊ុនតាក់ត្រូវបានបង្កើតឡើង ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ៧៤៥ ( ១៩៩២ ) និងត្រូវបានអនុវត្តនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩២។ អ៊ុនតាក់មានភារកិច្ចដឹកនាំកម្ពុជាឆ្លងកាត់ដំណាក់កាលអន្តរកាលទៅរកការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅនៅ ខែមេសា ឬខែឧសភា ឆ្នាំ១៩៩៣ ក្នុងគោលបំណង បង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យមួយ។ រូបថតៈ អង្គការសហប្រជាជាតិ I ប្រភពៈ Benny Widyono



កងទ័ពខ្មែរក្រហមនៅក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម។ រូបថតនេះថតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៩២។ រូបថត: អង្គការសហប្រជាជាតិ I ប្រភព: Benny Widyono

Khmer Rouge soldiers in a zone controlled by the Khmer Rouge. The photo was taken on January 01, 1992. Photo: UN Photo/J I Source: Benny Widyono



ស្ត្រីម្នាក់ទទួលសន្លឹកឆ្នោតពីបុគ្គលិក
បម្រើការបោះឆ្នោតរបស់អ៊ុនតាក់។
រូបថតនេះថតនៅខេត្តកំពង់ឆ្នាំង
នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣
នៅក្នុងពេលបោះឆ្នោត។
រូបថត៖ អង្គការសហប្រជាជាតិ/ P Sudhakaran
ប្រភព៖ Benny Widyono

A woman receiving her ballot from an UNTAC electoral staff member. The photo was taken at Kampong Chhanang on May 23, 1993 during the National Election. Photo: UN Photo/P Sudhakaran I Source: Benny Widyono




ក្រុមព័ត៌មាន និងអប់រំរបស់អ៊ុនតាក់
កំពុងធ្វើដំណើរទៅកាន់កោះមួយ
របស់កម្ពុជា ដើម្បីផ្សព្វផ្សាយអំពី
ដំណើរការបោះឆ្នោត។
ប្រភព: អង្គការសហប្រជាជាតិ
ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៣។

An UNTAC information education team heading towards a Cambodian island to publicize voting procedures.

Source: UN Photo 16 May 1993.



ប្រជាជនកម្ពុជាប្រមូលផ្តុំគ្នានៅក្បែរការិយាល័យបោះឆ្នោតមួយនៅខេត្តព្រៃវែង នៅថ្ងៃទីពីរនៃថ្ងៃបោះឆ្នោត ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣។
រូបថតនេះថតនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៣។ រូបថត: P Sudhakaran I ប្រភព: Benny Widyono

Cambodians assembled near a polling station in Prey Veng Province on the second day of voting. Voting, for a national constituent assembly, was being conducted under the supervision of UNTAC. The election was scheduled for 23-28 May 1993. The  photo was taken on May 24, 1993.
Photo: UN Photo/John Isaac I Source: Benny Widyono



កងកម្លាំងអង្កេតមួយរបស់អង្គការសហប្រជាជាតិកំពុងលេងជាមួយក្មេងម្នាក់ដែលជាកូនរបស់ជនជាតិដើមភាគតិចនៅខេត្តរតនគិរី ដែលជាខេត្តមួយសម្បូរទៅដោយ ជនជាតិដើមភាគតិច។ រូបថតនេះថតនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៣។ រូបថតៈ អង្គការសហប្រជាជាតិ/ John Isaac I ប្រភពៈ Benny Widyono

A united Nations Military Observer from the United states plays with a baby from the Krung-Brau tribe in Ratanankiri Province where have a lot of ethnic monirity living  as the child's mother looks on. The Photo was taken on May 04, 1993. Photo: UN Photo/John Isaac I Source: Benny Widyono




A United Nations staff member counts the votes at the Electoral Warehouse in Phnom Penh on May 23, 1993.
Photo: UN Photo/P Sudhakaran
Source: Benny Widyono

បុគ្គលិករបស់អង្គការសហប្រជាជាតិកំពុងរាប់សន្លឹកឆ្នោតនៅកន្លែងទុកសន្លឹកឆ្នោតនៅទីក្រុងភ្នំពេញ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣។
រូបថតៈ អង្គការសហប្រជាជាតិ/ P Sudhakaran I ប្រភពៈ Benny Widyono




បុគ្គលិកម្នាក់របស់ការិយាល័យទំនាក់
ទំនងសហគមន៍របស់អ៊ុនតាក់កំពុងជួស
ជុលហ្វ្រាំងស៊ីក្លូនៅទីក្រុងភ្នំពេញ
នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៩៣។
រូបថត៖ អង្គការសហប្រជាជាតិ /
P Sudhakaran
ប្រភព៖ Benny Widyono

An UNTAC staff member ( centre, kneeling ) of the Community Relations Office fixes a safety reflector on a cyclo in phnom Penh on June 01, 1993. Photo: UN Photo/P Sudhakaran I Source:  Benny Widyono



ប្រធានអ៊ុនតាក់ អាកាស៊ី, ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ, ឧត្តមសេនីយ៍ សេនឌឺសុន មកពីប្រទេសអូស្ត្រាលី ដែលជាមេបញ្ជាការកងកម្លាំងរបស់អ៊ុនតាក់, កងអង្គរក្សរបស់សម្តេច សីហនុ មកពីប្រទេសកូរ៉េខាងជើង បានធ្វើដំណើរមកខេត្តសៀមរាប ដើម្បីចូលរួមសម្ពោធទីស្នាក់ការប្រចាំខេត្តរបស់អ៊ុនតាក់ ដែលដឹកនាំដោយ Benny Widyono។
ប្រភព: Benny Widyono

Akashi, the head of UNTAC, King Sihanouk, General Sanderson from Australia the force commander of UNTAC and body guards from North Korea for the King arriving in Siemreap to open the provincial headquarters of UNTAC Governor Benny Widyono. Source: Benny Widyono




ការស្វាគមន៍ការធ្វើមាតុភូមិនិវត្ត
របស់ជនភៀសខ្លួនទី ១០០,០០០
ពីជំរំជនភៀសខ្លួននៅប្រទេសថៃ។
រូបថត: អង្គការសហប្រជាជាតិ /
P Sudhakaran នៅថ្ងៃទី២៨
ខែសីហា ឆ្នាំ១៩៩២ទីក្រុងភ្នំពេញ។
ប្រភព: Benny Widyono

Welcome home of 100,000th refugee from refugee camps in Thailand. Photo: UN Photo/ Sudhakaran on 28 August 1992, Phnom Penh, Cambodia. Source: Benny Widyono



តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ យ៉ាសុស៊ី អាកាស៊ី (រូបទីពីររាប់ពីឆ្វេង) កំពុងប្រជុំជាមួយអភិបាលខេត្ត។ រូបនៅខាងឆ្វេងបំផុត ជាទីប្រឹក្សាផ្នែកនយោបាយ Ataul KARIM។ រូបទីពីររាប់ពីស្ដាំ ជានាយកផ្នែករដ្ឋបាលស៊ីវិល Gerald PORCELL និងអ្នកសម្របសម្រួលប្រចាំខេត្ត Ben Yahmed JAMAIL។ រូបថតនេះថតនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ នៅទីស្នាក់ការកណ្ដាលរបស់អ៊ុនតាក់ នៅទីក្រុងភ្នំពេញ។ រូបថតៈ អង្គការសហប្រជាជាតិ I ប្រភពៈ Benny Widyono

Yasushi AKASHI ( second from left ), special Representative of the Secretary-General addresses a meeting of provinicia1 directors. On the extreme left is Ataul KARIM, political Advisor; Gerald PORCELL ( second from right ), Director, Civil Administration Component and Ben Yahmed JAMAIL, provincial coordinator. The photo was taken on May 23, 1993 at UNTAC Head Quarter in Phnom Penh. Photo: UN Photo/P I Source: Benny Widyono



Cambodians returning from refugee camps in Thailand aboard a UNHCR train approaching Phnom Penh June 1992. Source: Benny Widyono

ប្រជាជនកម្ពុជាធ្វើមាតុភូមិនិវត្តពីជំរំជនភៀសខ្លួននៅប្រទេសថៃតាមរយៈរថភ្លើងដែលរៀបចំដោយឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួន របស់អង្គការសហប្រជាជាតិ សំដៅមកទីក្រុងភ្នំពេញ នៅខែមិថុនា ឆ្នាំ១៩៩២។ ប្រភព: Benny Widyono




ឧទ្ធម្ភាគចក្រសូវៀត MI26 ដែលជាឧទ្ធម្ភាគចក្រធំជាងគេបំផុត អាចផ្ទុករថយន្តបាន៣គ្រឿងក្នុងពេលតែមួយ ត្រូវបានអ៊ុនតាក់ជួលមកដឹករថយន្ត និងកងកម្លាំងរបស់អ៊ុនតាក់។ រូបថត៖ អង្គការសហប្រជាជាតិ/ Sudhakaran (មិនដឹងកាលបរិច្ឆេទ) I ប្រភព៖ Benny Widyono

A giant Soviet made helicopter MI26, the largest in the world, which can transport three vehicles at one time, hired by UNTAC to transport UNTAC vehicles and soldiers. Photo: UN photo/ Sudhakaran, Date unknown I Source: Benny Widyono




Benny Widyono អមដំណើរជាមួយ
មេបញ្ជាការកងទ័ពខេត្ត វរសេនីយ៍ឯក Kamal
និងអគ្គនាយក Dowing មកពីនគរបាល Irih
(រូបបាំងដោយផ្នែក) កំពុងត្រួតពិនិត្យកងកម្លាំង
និងបុគ្គលិកស៊ីវិលរបស់អង្គការសហប្រជាជាតិនៅ
ពហុកីឡដ្ឋានខេត្តសៀមរាប នៅថ្ងៃទី២៤
ខែតុលា ឆ្នាំ១៩៩២។ ប្រភព: Benny Widyono

BennyWidyono flanked by the Provincial Military Commander Colonel Kamal and Superintedent Dowing from the Irih police ( partly hidden ) inspecting UN troops and civilian personnel at Siem Reap stadium on UN day 24 october 1992. Source: Benny Widyono



Benny Widyono ឈរក្នុងចំណោមកងទ័ពខ្មែរក្រហមនៅប៉ៃលិន ដែលជាទីស្នាក់ការកណ្តាលរបស់ខ្មែរក្រហម នៅជាប់ព្រំដែនថៃ ជាតំបន់មួយដែលមមាញឹកនឹងការជួញដូរត្បូងមានតម្លៃ និងព្រៃឈើជាមួយឈ្មួញជនជាតិថៃ។ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានអញ្ជើញ Benny Widyono អមដំណើរជាមួយទ្រង់ ដើម្បីត្រួតពិនិត្យតំបន់ខ្មែរក្រហម នៅខែកញ្ញា ឆ្នាំ១៩៩២។ ប្រភព: Benny Widyono

Benny Widyono standing among the Khmer Rouge troops in Pailin, the headquarters of the Khmer Rouge territory bordering on Thailand which carried out a busy gems and logs trade with Thai traders. Widyono was asked to accompany King Sihanouk to inspect KR territories. September 1992. Source: Benny Widyono

--

ពិព័រណ៍នេះរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

dccam@online.com.kh I www.dccam.org

ឧបត្ថម្ភដោយ បណ្តាញប្រជាធិបតេយ្យអាស៊ី

គាំទ្រដោយ ទីភ្នាក់ងារអាមេរិកសម្រាប់ការអភិវឌ្ឍ ស្ថានទូតអាមេរិកប្រចាំកម្ពុជា និង Maureen Lambray

This exhibition is prepared by Documentation Center of Cambodia ( DC-Cam )

dccam@online.com.kh I www.dccam.org

Funded by Asia Democracy Network ( ADN )

With the support from USAID, U.S. Embassy Phnom Penh, Maureen Lambray